ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ : 602 អ.រតន.

រាជធានីភ្នំពេញ ថ្ងៃទី 06 ខែ 3 ឆ្នាំ២០១៣

# សេចក្ដីណែនាំ
## ស្ដីពី
## លំហូរថវិការបស់ឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៣

យោងលិខិតលេខ១២៤២សហវ-ហម ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ ស្ដីពីការផ្ទេរធនធានពីគណនីមូលនិធិឃុំ សង្កាត់ទៅគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលឃុំ សង្កាត់សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ។

ដើម្បីសម្រួលដល់កិច្ចបញ្ជិកាគណនេយ្យនៅរតនាគារថ្នាក់កណ្ដាល និងនៅរតនាគាររាជធានី ខេត្តទាក់ទងនឹងលំហូរថវិការបស់ឃុំ សង្កាត់នៅឆ្នាំ២០១៣ អគ្គនាយកដ្ឋានរតនាគារជាតិសូមធ្វើសេចក្ដីណែនាំដូចមានខ្លឹមសារខាងក្រោម៖

### ១. នៅរតនាគារថ្នាក់កណ្ដាល

**១.១-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបោះផ្សាយអាណត្តិបើកប្រាក់ផ្ដល់ឧបត្ថម្ភធនឱ្យឃុំ សង្កាត់ ។

**ការកត់ត្រា ៖**

**ឥណពន្ធ** គណនីឧបត្ថម្ភធនដល់ឃុំ សង្កាត់ ( លេខ ៦៥១៣ )

**ឥណទាន** គណនីមូលនិធិឃុំ សង្កាត់ ( លេខ ៤៦៤៣ ) ។

**១.២-** នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃត្រូវរៀបចំប័ណ្ណផ្ទេរភារៈចំណាយ ផ្ទេរវិភាជន៍ឥណទានថវិកាឱ្យឃុំ សង្កាត់ជាពីរផ្នែកដាច់ដោយឡែកពីគ្នា គឺមួយផ្នែកសម្រាប់ឃុំ និងមួយផ្នែកទៀតសម្រាប់សង្កាត់ ។

**១.៣-** ពេលទទួលបានប័ណ្ណផ្ទេរភារៈចំណាយពីនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ, នាយកដ្ឋានគណនេយ្យនៃអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវរៀបចំប្រកាសឥណទានផ្ទេរវិភាជន៍ថវិកាជាពីរផ្នែកដាច់ដោយឡែកពីគ្នាគឺមួយផ្នែកសម្រាប់ឃុំ និងមួយផ្នែកទៀតសម្រាប់សង្កាត់ ។

**ការកត់ត្រា ៖**

**ឥណពន្ធ** គណនីមូលនិធិឃុំ សង្កាត់ ( លេខ ៤៦៤៣ )

**ឥណទាន** គណនីទំនាក់ទំនងរវាងរតនាគារថ្នាក់កណ្ដាល និងរតនាគាររាជធានី ខេត្ត ( លេខ ៤៥៨.១.៤ ) ។

### ២. នៅរតនាគាររាជធានី ខេត្ត

**២.១- ការកត់ត្រាក្នុងគណនេយ្យរដ្ឋ ៖**

២.១.១- ពេលទទួលបានប្រកាសឥណទានផ្ទេរវិភាជន៍ថវិកាពីរតនាគារថ្នាក់កណ្ដាល កត់ត្រា៖

**ឥណពន្ធ** គណនីទំនាក់ទំនងរវាងរតនាគាររាជធានី ខេត្ត និងរតនាគារថ្នាក់កណ្ដាល ( លេខ ៤៥៨.២.៤ )

**ឥណទាន** គណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ ( លេខ ៤៧០.៨ ) ។

២.១.២- ឥណទានសម្រាប់ថវិការបស់**ឃុំ** ត្រូវកត់ត្រាទៅក្នុងគណនីប្រាក់បញ្ញើថវិការបស់ឃុំនីមួយៗ៖

**ឥណពន្ធ** គណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ ( លេខ ៤៧០.៨ )

**ឥណទាន** គណនីប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ ( លេខ៤៤២៣ ) ។

២.១.៣- ឥណទានសរុបថវិការបស់**សង្កាត់** ត្រូវកត់ត្រាទៅក្នុងគណនីប្រាក់បញ្ញើថវិការបស់រាជធានី ក្រុង

**ឥណពន្ធ** គណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ ( លេខ ៤៧០.៨ )

**ឥណទាន** គណនីប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ ( លេខ៤៤២២ ) ។

២.១.៤- ពេលទទួលបានឥណទានថវិកាដែលផ្តល់ឧបត្ថម្ភកធនបន្តពីថវិការាជធានី ក្រុង ត្រូវកត់ត្រាទៅក្នុងគណនីប្រាក់បញ្ញើថវិការបស់សង្កាត់និមួយៗ ៖

**ឥណពន្ធ** គណនីប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ( លេខ៤៤២២ )

**ឥណទាន** គណនីចំណូលផ្សេងៗ និងបង្វែររង់ចាំដោះស្រាយ ( លេខ៤៧០.៨ ) ឬ

**ឥណពន្ធ** គណនីប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ( លេខ៤៤២២ )

**ឥណទាន** គណនីប្រាក់បញ្ញើថវិការបស់ឃុំ សង្កាត់ ( លេខ៤៤២៣) ។

**២.២ ការកត់ត្រាក្នុងគណនេយ្យថវិការាជធានី ក្រុង ៖**

២.២.១- កត់ត្រាទៅក្នុងគណនេយ្យថវិការាជធានី ក្រុងនូវឥណទានថវិកាសរុបរបស់សង្កាត់ចំណុះរាជធានី ក្រុង ដែលបានទទួលពីថ្នាក់កណ្តាល៖

**ឥណពន្ធ** គណនីប្រាក់បញ្ញើរបស់រាជធានី ក្រុង នៅរតនាគារ ( លេខ ៥១៥២ )

**ឥណទាន** គណនីទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ ( លេខ ៧៥១ ) ។

២.២.២- សាលារាជធានី ក្រុងត្រូវបោះផ្សាយអាណត្តិបើកប្រាក់សរុបផ្តល់ឧបត្ថម្ភកធនដល់សង្កាត់ចំណុះ កត់ត្រា៖

**ឥណពន្ធ** គណនីឧបត្ថម្ភកធនដល់ឃុំ សង្កាត់ ( លេខ ៦៥១២ )

**ឥណទាន** គណនីប្រាក់បញ្ញើរបស់ថវិកាក្រុង ស្រុកនៅរតនាគារ ( លេខ ៥១៥២ )។

**២.៣ ការកត់ត្រាក្នុងគណនេយ្យថវិកាឃុំ ៖**

២.៣.១- ចំណូលសម្រាប់ចំណាយដំណើរការរដ្ឋបាល ៖

**ឥណពន្ធ** គណនីសាច់ប្រាក់ដែលឃុំ សង្កាត់ត្រូវទទួលពីរាជរដ្ឋាភិបាលឆ្នាំនេះ ( លេខ ៤១០៣០ )

**ឥណទាន** គណនីទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ ( លេខ ៧៥១ ) ។

២.៣.២- ចំណូលសម្រាប់ចំណាយអភិវឌ្ឍន៍ ៖

**ឥណពន្ធ** គណនីសាច់ប្រាក់ដែលឃុំ សង្កាត់ត្រូវទទួលពីរាជរដ្ឋាភិបាលឆ្នាំនេះ ( លេខ ៤១០៣០ )

**ឥណទាន** គណនីនៃការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន ( លេខ ៧៥៤ ) ។

**២.៤ ការកត់ត្រាក្នុងគណនេយ្យថវិកាសង្កាត់ ៖**

២.៤.១- ចំណូលសម្រាប់ចំណាយដំណើរការរដ្ឋបាល ៖

**ឥណពន្ធ** គណនីសាច់ប្រាក់ដែលឃុំ សង្កាត់ត្រូវទទួលពីរាជរដ្ឋាភិបាលឆ្នាំនេះ ( លេខ ៤១០៣០ )

**ឥណទាន** គណនីទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ ( លេខ ៧៥៣ ) ។

២.៤.២- ចំណូលសម្រាប់ចំណាយអភិវឌ្ឍន៍ ៖

**ឥណពន្ធ** គណនីសាច់ប្រាក់ដែលឃុំ សង្កាត់ត្រូវទទួលពីរាជរដ្ឋាភិបាលឆ្នាំនេះ ( លេខ ៤១០៣០ )

**ឥណទាន** គណនីនៃការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន ( លេខ ៧៥៤ ) ។

ទទួលបានសេចក្តីណែនាំនេះសូមលោកប្រធានគ្រប់នាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានរតនាគារជាតិ និង លោក-លោកស្រីប្រធានគ្រប់រតនាគាររាជធានី ខេត្តចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

ទីន_យន

**ចម្លងជូន:**

- នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីសហការអនុវត្ត"
- នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាននៃគ ជ អ ប
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ